ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3

លេខ. ០៨៣ ព.ម.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងផ្សព្វផ្សាយអាហ្វីស ប៉ាណូ បណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម

r ° s

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាន រដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន ។

-បានឃើញលិខិតលេខ ៥៨០ ព.សប្រក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ប៉ាណូ បណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈដែលមានលក្ខណៈឃោសនា មហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម ។

## សម្រេច

**ប្រកាស១** : ប្រកាសនេះមានគោលបំណងគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ប៉ាណូ បណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ រាល់ការផ្សព្វផ្សាយអាហ្វីស ប៉ាណូ បណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម ត្រូវសុំការអនុញ្ញាតពីក្រសួងព័ត៌មាន ។

**ប្រកាស២** :អ្នកផ្សព្វផ្សាយត្រូវបំពេញសំណុំបែបបទនៅអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ដូចខាងក្រោម:

១. ពាក្យសុំអនុញ្ញាតផ្សព្វផ្សាយ

២. ប្រវត្តិរូបសង្ខេបមានបិទរូបថត

៣. កិច្ចសន្យា

Create PDF files without this message by purchasing novaPDF printer (http://www.novapdf.com)

**ប្រការ៣** : ការអនុញ្ញាតឱ្យផ្សព្វផ្សាយ អាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និង ការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម មានសុពលភាពរយៈពេលកំណត់ទៅតាមការស្នើសុំ របស់អ្នកផ្សព្វផ្សាយរយៈពេល បីខែ ប្រាំមួយខែ និង មួយឆ្នាំ ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៥** : អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ខុទ្ទកាល័យ មន្ទីរ ព័ត៌មានខេត្ត-រាជធានី ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

**<u>ចម្លងជូន</u>** :

-លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន

-ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-ក្រសួងមហាផ្ទៃ

-គ្រប់ក្រសួង-ស្ថាប័ន

-សាលាខេត្ត-រាជធានី

"ដើម្បីរួមសហការអនុវត្ត"

-ដូចប្រការ ៥ "ដើម្បីអនុវត្ត"

-រាជកិច្ច

Create PDF files without this message by purchasing novaPDF printer (http://www.novapdf.com)